អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ពួកយើងទាំងអស់ខុសគ្នា**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ(អំពីរាងកាយផ្ទាល់ខ្លួន)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។

បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(វិទ្យាសាស្ត្រ)** ប្រាប់ឈ្មោះអំពីរាងកាយរបស់មនុស្សឱ្យបាន ៦ផ្នែក។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសគូររូប, ខ្មៅដៃពណ៌

**ការរៀបចំ** ៖ ការរៀបចំកុមារជាក្រុមខាងក្រៅ និងក្រុមខាងក្នុង។

**សេចក្តីណែនាំ៖**

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងនិទានរឿង"យក្សចម្លែក" ឱ្យកូនស្តាប់ទាំងអស់គ្នា។ (បើក្មេងៗធ្លាប់ស្តាប់ហើយមិនបាច់និទាន សួរសំណួរតែម្តងក៏បាន)។
2. សួរក្មេងៗថា៖ចូរកូនៗគិតពីតួរអង្គនៅក្នុងសៀវភៅរឿង"យក្សចម្លែក" នេះម្តងមើល! តើពួកគេទាំងអស់ដូចគ្នាដែរឬទេ? ចាស/បាទ មិនដូចគ្នាទេ។
   តើតួរអង្គនីមួយៗមានលក្ខណៈដូចគ្នា និងខុសគ្នាបែបណាខ្លះ?
   យ៉េកមានកម្ពស់ខ្ពស់ រតនា មានសក់វែង មករា សក់ខ្លី.....
3. សួរក្មេងៗថា៖តើមានក្មេងណាមានរូបរាងដូចគ្នាដែរឬទេ?
   ពួកគេអាចកត់សម្គាល់ថាគ្រប់គ្នាមើលទៅខុសគ្នា ទោះបីជាក្មេងៗខ្លះប្រជៀងគ្នាក៏ដោយ។
4. បង្កើតសំណួរទាក់ទងនឹងរាងកាយមនុស្ស៖
   តើកូនៗណាខ្លះដែលមានភ្នែកមួយគូរ ឬពីរសូមលើកដៃ?

(មាត់ ច្រមុះ សក់ ត្រចៀក ក្បាល ដៃមួយពីរ ជើងពីរ)

ឱ្យក្មេងៗលើកដៃទាំងអស់គ្នា ប្រសិនបើពួកគេមានភ្នែកមួយគូរ។

5. និយាយថា៖ កូនៗទាំងអស់គ្នានិយាយថាគ្មាននរណាម្នាក់មានរូបរាងដូចគ្នានោះទេ។

    ចុះហេតុអ្វីបានជាមនុស្សគ្រប់គ្នាមានភ្នែកពីរ ត្រចៀកពីរដូចគ្នា?

    អញ្ចឹងមានតែអ្នកទាំងអស់គ្នាមើលទៅដូចគ្នា?។

    មិនដូចគ្នាទេ។

6. និយាយថា "អ្នកមានភ្នែកពីរគឺដូចជាអ្នកគ្រូដែរ (ដាក់ឈ្មោះក្មេងណាម្នាក់ទៀតក៏បាន)។ ដូច្នេះហេតុអ្វីបានជាអ្នកខុសគ្នាពីអ្នកគ្រូ? " ធ្វើបែបនេះម្តងទៀតសម្រាប់កុមារ និងផ្នែករាងកាយពីរបីផ្សេងទៀត។

7. សួរក្មេងៗ៖ តើកូនណាជាក្មេងស្រីសូមលើកដៃ? ឱ្យក្មេងលើកដៃ ប្រសិនបើជាក្មេងស្រី។ ឬក្មេងប្រុស មានសក់វែងពាក់វ៉ែនតា និងលក្ខណៈផ្សេងទៀតដែលពួកគេទាំងអស់មិនមានដូចគ្នា។

8. សួរក្មេងៗ៖ តើកូនៗជ្រើសរើសលេងជាមួយនរណាម្នាក់ដោយសារតែពួកគេមានសក់វែង ឬសក់ខ្លី?

    បាទ/ចាស មិនមែនដោយសារបែបហ្នឹងទេ។

    តើកូនៗគិតបែបហ្នឹងត្រឹមត្រូវដែរឬទេ? បាទ/ចាស មិនត្រឹមត្រូវទេ។

9. សួរក្មេងៗ៖ តើកូនៗគួរជ្រើសរើសលេងជាមួយនរណាម្នាក់ដោយសារតែពួកគេមកពីប្រទេសផ្សេងមែនដែរឬទេ? បាទ/ចាស មិនមែនទេ។

    តើយុត្តិធម៌ដែរឬទេ? បាទ/ចាស មិនយុត្តិធម៌ទេ។

10. ឱ្យក្មេងៗឈរជាពីរង្វង់ ក្រុមក្នុង និងក្រុមក្រៅ។

11. ក្រុមខាងក្នុងគួរតែបែរមុខទៅខាងក្រៅ ក្រុមខាងក្រៅគួរតែបែរមុនមកខាងក្នុងវិញ។ ដូច្នេះក្មេងទាំងអស់នឹងអាចឈរទល់មុខគ្នា។

12. ប្រាប់ពីសេចក្តីណែនាំទាំងនេះ និងការណែនាំស្របទៅតាមសកម្មភាពនេះ៖

    - ត្រូវឱ្យក្មេងៗដែលចាប់គូរគ្នា ហើយកាន់ដៃគ្នាដែរ។
    - កុមារនៅក្នុងរង្វង់ខាងក្នុងគួរតែនិយាយថា៖

      "ខ្ញុំគឺដូចគ្នានឹងអ្នកដែរពីព្រោះខ្ញុំមានភ្នែកពីរដូចគ្នា…។

      "ខ្ញុំខុសពីអ្នកព្រោះខ្ញុំមានសក់ខ្លីជាងអ្នក…។ និយាយម្នាក់ម្តង
    - បន្ទាប់មកក្មេងៗនៅខាងក្រៅគួរតែរំកិលបន្តិចទៅខាងស្តាំ ដូច្នេះពួកគេកំពុងនៅទល់មុខនឹងដៃគូថ្មីរបស់ពួកគេ។
    - ក្មេងៗគួរធ្វើសកម្មភាពម្តងទៀតជាមួយដៃគូថ្មីដោយព្យាយាមប្រើឧទាហរណ៍ផ្សេងៗ។

13. បន្តសកម្មភាពរង្វង់ឱ្យយូរដូចដែលអ្នកចង់បាន តាមឧត្តមគតិឱ្យកុមារនិយាយជាមួយកុមារយ៉ាងហោចណាស់បីនាក់ផ្សេងទៀត។
14. បន្ទាប់មកឱ្យក្រដាសគូររូប និងខ្មៅដៃពណ៌ផាត់។
15. សុំឱ្យពួកគេគូរមនុស្សពីរនាក់ដែលមានលក្ខណៈពិសេសបីដូចគ្នា និងលក្ខណៈពិសេសបីផ្សេងទៀតដែលខុសពីគ្នា។